តម្លាភាពកម្ពុជា
TRANSPARENCY INTERNATIONAL Cambodia

# សន្ទស្សន៍នៃការយល់ឃើញពីអំពើពុករលួយ ឆ្នាំ២០២៣

## អំពើពុករលួយ និងភាពអយុត្តិធម៌

## ការបង្ហាញលទ្ធផល

ប៉ិច ពិសី
នាយកប្រតិបត្តិ
អង្គការតម្លាភាពកម្ពុជា

ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៤

Collective Actions Against Corruption

# CPI 2023: បណ្តាប្រទេសទទួលបានពិន្ទុខ្ពស់ទាំង ១១

តម្លាភាពកម្ពុជា
TRANSPARENCY INTERNATIONAL Cambodia

| ចំណាត់ថ្នាក់ | ប្រទេស/ដែនដី | ពិន្ទុ |
|---|---|---|
| ១ | ដាណឺម៉ាក | ៩០ |
| ២ | ហ្វាំងឡង់ | ៨៧ |
| ៣ | នូវែលសេឡង់ | ៨៥ |
| ៤ | ណ័រវេ៉ | ៨៤ |
| ៥ | សឹង្ហបុរី | ៨៣ |
| ៦ | ស៊ុយអែត | ៨២ |
| ៦ | ស្វីស | ៨២ |
| ៨ | ហូឡង់ | ៧៩ |
| ៩ | លុចសំបួរ | ៧៨ |
| ៩ | អាល្លឺម៉ង់ | ៧៨ |
| ១១ | អៀរឡង់ | ៧៧ |

# CPI 2023: បណ្តាប្រទេសទទួលបានពិន្ទុទាបទាំង ១១



| ចំណាត់ថ្នាក់ | ប្រទេស/ដែនដី | ពិន្ទុ |
|---|---|---|
| ១៧០ | លីប៊ី | ១៨ |
| ១៧០ | តួកមេនីស្ថាន | ១៨ |
| ១៧២ | អេក្វាទ័រហ្គីណេ | ១៧ |
| ១៧២ | ហៃទី | ១៧ |
| ១៧២ | សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ (កូរ៉េខាងជើង) | ១៧ |
| ១៧២ | នីការ៉ាក្វា | ១៧ |
| ១៧៦ | យេម៉ែន | ១៦ |
| ១៧៧ | វ៉េណេស៊ុយ អេឡា | ១៣ |
| ១៧៧ | ស៊ីរី | ១៣ |
| ១៧៧ | ស៊ូដង់ខាងត្បូង | ១៣ |
| ១៨០ | សូម៉ាលី | ១១ |

# ការប្រៀបធៀបពីការប្រែប្រួលពិន្ទុរបស់បណ្តាប្រទេសពិន្ទុខ្ពស់ទាំង ១១ (២០២២ - ២០២៣)

ត្លាភាពកម្ពុជា
TRANSPARENCY INTERNATIONAL Cambodia



# ការប្រៀបធៀបពីការប្រែប្រួលពិន្ទុរបស់បណ្ដាប្រទេស ពិន្ទុទាបទាំង ១១ (២០២២ - ២០២៣)




Collective Actions Against Corruption

# CPI 2023: CAMBODIA



- ប្រទេសកម្ពុជាទទួលបានពិន្ទុ ២២ ក្នុងសន្ទស្សន៍នៃការយល់ឃើញពីអំពើពុករលួយឆ្នាំ ២០២៣ ដែលពិន្ទុនេះមានការធ្លាក់ចុះ ២ ពិន្ទុ បើប្រៀបធៀបជាមួយនឹងពិន្ទុឆ្នាំ ២០២២ គឺកម្ពុជាទទួលបានពិន្ទុ ២៤ ក្នុងចំណោមពិន្ទុពេញ ១០០
- ប្រទេសកម្ពុជាស្ថិតនៅក្នុងចំណាត់ថ្នាក់ទី ១៥៨ ក្នុងចំណោមប្រទេសទាំង ១៨០ ដែលបានដាក់បញ្ចូលក្នុងការសិក្សាវាយតម្លៃនេះ។ ចំណាត់ថ្នាក់របស់ប្រទេសកម្ពុជាក្នុងឆ្នាំ ២០២៣ នេះ ក៏មានការធ្លាក់ចុះពីចំណាត់ថ្នាក់ទី ១៥០ ក្នុងឆ្នាំ ២០២២ ផងដែរ។
- ប្រទេសកម្ពុជានៅតែស្ថិតចំណាត់ថ្នាក់ទាបលំដាប់ទី២ក្នុងតំបន់អាស៊ាន ដែលនាំមុខប្រទេសមីយ៉ាន់ម៉ាតែមួយប៉ុណ្ណោះ ហើយនិងស្ថិតក្នុងចំណាត់ថ្នាក់ទាបទី ៤ ក្នុងបណ្តាប្រទេសក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។

# ការប្រៀបធៀបពិន្ទុនៃសន្ទស្សន៍នៃការយល់ឃើញពីអំពើពុករលួយ សម្រាប់ប្រទេសកម្ពុជា ពីឆ្នាំ ២០១២ - ២០២៣

តម្លាភាពកម្ពុជា
TRANSPARENCY INTERNATIONAL
Cambodia



# CPI 2023: ប្រភពទិន្នន័យសម្រាប់ប្រទេសកម្ពុជា

តម្លាភាពកម្ពុជា TRANSPARENCY INTERNATIONAL Cambodia

| | | | |
|---|---|---|---|
| 1 | សន្ទស្សន៍នៃការបម្រែបម្រួលរបស់មូនិធិ Betelsman BF(TI) | Bertelsmann Stiftung | ធ្វើការវិភាគ និងប្រៀបធៀបប្រទេសលើស្ថានភាពប្រជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញ សេដ្ឋកិច្ចទីផ្សារដែលមានទំនួលខុសត្រូវសង្គម និងអភិបាលកិច្ច |
| 2 | ចំណាត់ថ្នាក់ហានិភ័យប្រចាំប្រទេសរបស់ទីភ្នាក់ងារសេដ្ឋវិទូ | Economist Intelligence Unit (EIU) | រៀបចំឡើងដើម្បីផ្តល់នូវការវិភាគស៊ីជម្រៅ និងទាន់ពេលវេលាចំពោះហានិភ័យនៃការវិនិយោគ |
| 3 | ចំណាត់ថ្នាក់ហានិភ័យប្រចាំប្រទេសស្តីពីការយល់ដឹងជាសកល | Global Insights (GI) | ផ្តល់នូវការវិភាគហានិភ័យ ដោយផ្អែកលើកត្តាចំនួន ៦ រួមមានហានិភ័យនយោបាយ សេដ្ឋកិច្ច ច្បាប់ ពន្ធ ប្រតិបត្តិការ និងសន្តិសុខ |
| 4 | ទីភ្នាក់ងារប្រឹក្សាហានិភ័យនយោបាយនិងសេដ្ឋកិច្ចទ្វីបអាស៊ី | Political and Economic Risk Consultancy (PERC) | ផ្តោតការវិភាគជាពិសេសលើកត្តាសង្គម-នយោបាយសំខាន់ៗ រួមមានអំពើពុករលួយ កម្មសិទ្ធិបញ្ញានិងហានិភ័យ គុណភាពការងារនិងភាពខ្លាំងនិងភាពខ្សោយនៃប្រព័ន្ធគ្រប់គ្រងរបស់ប្រទេសឬដែនដីនីមួយនៃទ្វីបអាស៊ី |
| 5 | ការវាយតម្លៃស្ថាប័ន និងគោលនយោបាយប្រចាំប្រទេសរបស់ធនាគារពិភពលោក (CPIA) | World Bank | វាយតម្លៃលើគុណភាពនៃក្របខ័ណ្ឌគោលនយោបាយ និងស្ថាប័នរបស់ប្រទេសនីមួយៗ ក្នុងការការកាត់បន្ថយភាពក្រីក្រ កំណើនប្រកបដោយចីរភាព និងការប្រើប្រាស់ជំនួយអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព |
| 6 | សន្ទស្សន៍ស្តីពីនីតិរដ្ឋរបស់គម្រោងយុត្តិធម៌ពិភពលោក | World Justice Project (WJP) | ) វាយតម្លៃលើការប្រកាន់ខ្ជាប់របស់ប្រទេសនីមួយៗចំពោះការអនុវត្តនីតិរដ្ឋ កំណត់នូវចំណុចខ្លាំងនិងចំណុចខ្សោយ និងតាមដានការផ្លាស់ប្តូររបស់ប្រទេសទាំងនោះ |
| 7 | គម្រោងនៃភាពផ្សេងគ្នានៃប្រជាធិបតេយ្យ | The V-Dem institute (V-Dem) | ជាវិធីសាស្រ្តថ្មីមួយដែលផ្តល់ទស្សនទាន និងវាស់វែងពីការអនុវត្តលទ្ធិប្រជាធិបតេយ្យ ដោយផ្តល់នូវសំណុំទិន្នន័យពហុជាតិ និងលម្អិត ដែលឆ្លុះបញ្ចាំងពីភាពស្មុគស្មាញនៃគោលគំនិតរបស់ប្រជាធិបតេយ្យ ដែលជាប្រព័ន្ធគ្រប់គ្រងមួយ លើសពីវត្តមាននៃការបោះឆ្នោត |

# CPI 2023: ប្រភពទិន្នន័យសម្រាប់ប្រទេសកម្ពុជា

តម្លាភាពកម្ពុជា
TRANSPARENCY INTERNATIONAL
Cambodia




1. BF (TI) : សន្ទស្សន៍នៃការបម្រែបម្រួលរបស់មូលនិធិ Bertelsmann
2. EIU : ចំណាត់ថ្នាក់ហានិភ័យប្រចាំប្រទេសរបស់ទីភ្នាក់ងារសេដ្ឋវិទូ
3. GI : ចំណាត់ថ្នាក់ហានិភ័យប្រចាំប្រទេសស្ដីពីការយល់ដឹងជាសកល
4. PERC : ទីភ្នាក់ងារប្រឹក្សាហានិភ័យនយោបាយ និងសេដ្ឋកិច្ចទ្វីបអាស៊ី
5. VDEM : គម្រោងនៃភាពផ្សេងគ្នានៃប្រជាធិបតេយ្យ
6. WB : ការវាយតម្លៃស្ថាប័ន និងគោលនយោបាយប្រចាំប្រទេសរបស់ធនាគារពិភពលោក
7. WJP : សន្ទស្សន៍ស្ដីពីនីតិរដ្ឋរបស់គម្រោងយុត្តធម៌ពិភពលោក

# ការប្រៀបធៀបពិន្ទុតាមរយៈប្រភពទិន្នន័យសម្រាប់ប្រទេសកម្ពុជា ២០២២ - ២០២៣

តម្លាភាពកម្ពុជា
TRANSPARENCY INTERNATIONAL
Cambodia




1. BF (TI) : សន្ទស្សន៍នៃការបម្រែបម្រួលរបស់មូលនិធិ Bertelsmann 2024 vs 2022
2. EIU : ចំណាត់ថ្នាក់ហានិភ័យប្រចាំប្រទេសរបស់ទីភ្នាក់ងារសេដ្ឋវិទូ 2023 vs 2022
3. GI : ចំណាត់ថ្នាក់ហានិភ័យប្រចាំប្រទេសស្ដីពីការយល់ដឹងជាសកល 2022 vs 2021
4. PERC : ទីភ្នាក់ងារប្រឹក្សាហានិភ័យនយោបាយ និងសេដ្ឋកិច្ចទ្វីបអាស៊ី 2023 vs 2022
5. VDEM : គម្រោងនៃភាពផ្សេងគ្នានៃប្រជាធិបតេយ្យ 2023 vs 2022
6. WB : ការវាយតម្លៃស្ថាប័ន និងគោលនយោបាយប្រចាំប្រទេសរបស់ធនាគារពិភពលោក 2022 vs 2021
7. WJP : សន្ទស្សន៍ស្ដីពីនីតិរដ្ឋរបស់គម្រោងយុត្តធម៌ពិភពលោក 2023 vs 2022

# CPI 2023 - ប្រទេសក្នុងតំបន់អាស៊ាន

តម្លាភាពកម្ពុជា
TRANSPARENCY INTERNATIONAL
Cambodia



# ការប្រៀបធៀបពិន្ទុ CPI ២០២៣ ក្នុងបណ្ដាប្រទេសក្នុងតំបន់អាស៊ាន

តម្លាភាពកម្ពុជា
TRANSPARENCY INTERNATIONAL Cambodia



# អនុសាសន៍សំខាន់ៗ

TRANSPARENCY INTERNATIONAL Cambodia

**អនុសាសន៍សំខាន់ៗពីអង្គការតម្លាភាពកម្ពុជាមានដូចជា៖**

- **ផ្តន្ទាទោសរាល់អំពើពុករលួយ៖** ផ្តន្ទាទោសយ៉ាងលឿនរហ័សរាល់អំពើពុករលួយ ទាំងទ្រង់ទ្រាយតូចឬធំ ដោយច្បាប់ប្រកបដោយប្រសិទ្ធភាព និងការអនុវត្តយ៉ាងម៉ឺងម៉ាត់។ ធ្វើឱ្យការប្រព្រឹត្តអំពើពុករលួយមានហានិភ័យខ្ពស់ និងគ្មានរង្វាន់។
- **ពង្រឹងគណនេយ្យភាពនិងការត្រួតពិនិត្យ៖** វប្បធម៌គណនេយ្យភាពទាមទារនូវការការពារនិងការលើកកម្ពស់សេរីភាពប្រជាធិបតេយ្យ រួមមានសេរីភាពនៃការបញ្ចេញមតិ សិទ្ធិនៃការជួបជុំ និងការប្រមូលផ្តុំ។ ការធានាយុត្តិធម៌សម្រាប់អ្នកការពារសិទ្ធិមនុស្ស និងការលើកកម្ពស់តួនាទីសំខាន់របស់ពួកគេក្នុងការត្រួតពិនិត្យគឺជារឿងសំខាន់បំផុត។ ស្ថាប័នសាធារណៈដែលទទួលបន្ទុកជាអ្នកត្រួតពិនិត្យ មានដូចជាទីភ្នាក់ងារប្រឆាំងអំពើពុករលួយ និងស្ថាប័នសវនកម្ម ត្រូវតែទទួលបានសិទ្ធិអំណាចនូវឯករាជ្យភាពនិងធនធានគ្រប់គ្រាន់ ដើម្បីស៊ើបអង្កេតនិងផ្តន្ទាទោសចំពោះអំពើខុសឆ្គង។ ប្រព័ន្ធតុលាការឯករាជ្យដែលមិនទទួលរងឥទ្ធិពលនយោបាយ មានសារៈសំខាន់ណាស់សម្រាប់ការត្រួតពិនិត្យអំណាចអង្គនីតិប្រតិបត្តិប្រកបដោយប្រសិទ្ធភាព។ ជាចុងក្រោយ ការបោះឆ្នោតប្រកបដោយតម្លាភាព និងយុត្តិធម៌ គឺជាកត្តាសំខាន់សម្រាប់ធានាថា ប្រជាពលរដ្ឋមានសំឡេងក្នុងការរៀបចំអនាគតរបស់ពួកគេ។
- **ធ្វើទំនើបកម្មក្របខ័ណ្ឌច្បាប់ប្រឆាំងអំពើពុករលួយ៖** ធ្វើបច្ចុប្បន្នភាពច្បាប់ប្រឆាំងអំពើពុករលួយឱ្យស្របតាមស្តង់ដារអន្តរជាតិ។ អនុម័តច្បាប់ការពារបុគ្គលអ្នករាយការណ៍ និងក្រមសីលធម៌វិជ្ជាជីវៈសម្រាប់មន្ត្រីសាធារណៈ។
- **លើកកម្ពស់តម្លាភាព និងការត្រួតពិនិត្យសាធារណៈ៖** ធានាសិទ្ធិទទួលបានព័ត៌មានតាមរយៈច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មានដ៏រឹងមាំ។ លើកកម្ពស់តម្លាភាពក្នុងការអនុវត្តរបស់រដ្ឋាភិបាលនិងការបែងចែកធនធាន។
- **កម្រិតនៃការប្រកួតប្រជែងសម្រាប់អាជីវកម្ម៖** លើកកម្ពស់តម្លាភាពសាជីវកម្ម និងការប្រកួតប្រជែងដោយយុត្តិធម៌។ លុបបំបាត់ភាពលំអៀងក្នុងលទ្ធកម្មសាធារណៈ និងធានាការគោរពច្បាប់ដោយស្មើភាពសម្រាប់អាជីវកម្មទាំងអស់។

សម្រាប់ការស្វែងរកព័ត៌មានបន្ថែម ឬ ឯកសារពាក់ព័ន្ធនានា សូមចូលទៅកាន់គេហទំព័ររបស់អង្គការតម្លាភាពកម្ពុជា

**TI Cambodia´s website:**

https://www.ticambodia.org/kh/home/ / www.ticambodia.org/cpi2023

TRANSPARENCY INTERNATIONAL Cambodia

**+855 23 88 36 81 / 88 36 82**

**Info@ticambodia.org**

**www.ticambodia.org**

**Transparency International Cambodia**

**@ticambodia**